# ១២

# តើយើងស្លាប់ទៅ សូន្យ ឬ កើតទៀត

ខ្ញុំ លើកពាក្យ កើត ស្លាប់ មកពេលនេះ ពីព្រោះមាន ចម្លើយមិនដូចគ្នា ចំពោះសំណួរថា តើ **ស្លាប់ហើយ កើតទៀត ឬ ក៏មិនកើតទៀត** ?

ខ្ញុំ គ្រាន់តែចង់រកហេតុផល នៃចម្លើយនីមួយៗនោះទេ ដោយពុំមានបំណងចង់ឲ្យ លោកអ្នកអាន មកយល់តាមខ្ញុំនោះទេ ពីព្រោះការយល់ខុសគ្នានេះ មានតាំងពីសម័យ មុនព្រះយើងម្ល៉េះ ។ មតិធំៗមានបី ៖

១- ស្លាប់ ហើយកើតទៀត ធ្លាប់កើតយ៉ាងណា កើតលើកក្រោយយ៉ាងនោះទៀត

២- ស្លាប់ ហើយ មិនកើតទៀតទេ គឺសូន្យតែម្តង

៣- ស្លាប់ហើយ អាចកើតទៀត ឬ មិនកើតទៀត ទៅតាមហេតុផ្សេងៗ ។

<u>មតិទី១-</u> សស្សតទិដ្ឋិ ជឿថាមានអត្តា <u>នៅរហូត</u> <u>មិនទាក់ទងនឹង</u> ការរីកចំរើន នៃ កាយនឹងចិត្ត ទោះក្នុងជាតិនេះក្តី ឬជាតិខាងមុខក្តី ។ បានន័យថា បើជាតិនេះ កើតមក ក្នុងពូជ ព្រាហ្មណ៍ ពីព្រោះកាលពី ជាតិមុនក៏ធ្លាប់ជា ព្រាហ្មណ៍ ហើយទៅជាតិ ខាងមុខ ក៏កើតជាព្រាហ្មណ៍តទៅទៀត ។ ដូច្នេះចំពោះ អ្នកកើត ក្នុងត្រកូលអ្នកក្រ ត្រកូលផ្សេងទៀតៗ គេមិនរាប់រកទេ ។

<u>មតិទី២-</u> ឧច្ឆេទទិដ្ឋិ ជឿថាមានអត្តា មានការរីកចំរើន នៃកាយនឹងចិត្ត ប្រហាក់ប្រហែល នឹងមតិទី១ ដែរ តែទាំងអស់នេះនឹងរលាយសោះសូន្យ ជាមួយនឹងសេចក្តីស្លាប់ ។ ត្រង់មតិនេះខ្ញុំមានសំណួរ តែខ្ញុំមិនចេះឆ្លើយ ។ សំណួរថា ៖ បើស្លាប់ទៅសូន្យ មិនកើតទៀត ចុះអ្នកដែលកើតមកដល់ថ្ងៃនេះ ចេញមកពីទីណា ពីមជ្ឈដ្ឋានណា ឬ ក៏

ធ្លាក់មកពីលើមេឃ ដោយចៃដន្យ ដូចទឹកភ្លៀង ។

ប្រសិនបើជាចេញពីមជ្ឈដ្ឋានណាមួយ

ហើយប្រសិនបើជា អ្នកដែលស្លាប់នោះមិនត្រឡប់ទៅកើតនៅ មជ្ឈដ្ឋាននោះវិញទេ មជ្ឈដ្ឋាននោះ មានអ្វីផ្តល់មកឲ្យកើតទៀត ពីព្រោះមានតែរបស់ចេញ ឥតមានរបស់ចូល ។ ចំពោះមេឃភ្លៀង គឺផ្តល់ដោយពពក ។ សំណួរមួយទៀត គឺមានកូនក្មេងដែល កើតមកហើយ ចាំជាតិ ។ ហេតុការណ៍នេះ មានទាំងនៅក្នុងស្រុកខ្មែរផង ទាំងនៅបរទេសទៀត ។ អំពីការចាំជាតិនេះ លោកបណ្ឌិត ម៉ែម ទីន មន សាស្ត្រាចារ្យ ជាតិភូមា បានប្រមូលកស្តុតាងជាច្រើន ដែលនៅសហរដ្ឋអាមេរិកក៏មាន នៅប្រទេសរបស់លោកក៏មាន ។ ចំពោះយើង ដែលជាអ្នកជឿព្រះពុទ្ធសាសនា និង ជឿធម៌ កម្មផល ពុំមានអ្វីប្លែកទេ ។ ពីព្រោះរឿង ក្នុងគម្ពីរទាំងប៉ុន្មាន ដែលទាក់ទងនឹង ការកសាងរបស់ព្រះពុទ្ធ សុទ្ធតែស្តីពី អតីតជាតិដ៏ច្រើន របស់ព្រះអង្គ មុននឹងដល់ជាតិចុងក្រោយ ដែលជាជាតិព្រះអង្គត្រាស់ដឹង ។ ដូចជាព្រះអង្គ ចាប់ជាតិជា ព្រះវេស្សន្តរ ជាដើម ។

ខ្ញុំសូមដកស្រង់រឿងមួយ ដែលមានក្នុងសៀវភៅ « កម្ម អ្នកសាងលោកពិត » របស់លោកបណ្ឌិត ម៉ែម ទីន មន ដូចតទៅនេះ ៖

នៅ មីយ៉ាម៉ា (ភូមា) ភាគកណ្តាលក្នុងភូមិមួយឈ្មោះ អ៊ិន ពីន ហ្វាក់ នៅសង្កាត់ ទាហ្គូន មានកូនក្មេងស្រីម្នាក់ កើតមកមានដុំសាច់ពកពីរ នៅលើក្បាលរបស់ខ្លួន ដូចជាស្នែងក្របី ។ នាងឈ្មោះ **ម៉ា ហ្តៃ** (Ma Htay) នៅពេលនាងអាចនិយាយបានច្បាស់ នាងបាននិយាយអំពី អតីតជាតិ ២ ដងរបស់នាង ។

ក្នុងអតីតជាតិទី ១ របស់នាង នាងឈ្មោះ **ឆ័រ ម៉្យាក់** នៅភូមិ **ញ៉ោងប៊ីន ជី** ។ **ឆ័រ ម៉្យាក់ បានជួល ម៉ា តេងទីន** ព្រមទាំងម្តាយនាង ឲ្យធ្វើការក្នុងស្រែរបស់ខ្លួន ។ **ម៉ា តេងទីន** ទើបតែមានអាយុ ១៣ ឆ្នាំ ប៉ុន្តែនាងមានរាងខ្ពស់មាំ ។ ដូច្នេះម្តាយរបស់នាង បណ្តោយ

ឲ្យនាង ធ្វើការដូចមនុស្សពេញវ័យដែរ ។ ប៉ុន្តែនៅពេល **ឪរ ម៉្វាក់** ឲ្យប្រាក់ថ្លៃឈ្នួលដល់ពួកគេ នាងឲ្យ **ម៉ា តេងទីន** តែថ្លៃពាក់កណ្ដាលនៃតម្លៃមនុស្សពេញវ័យ ដោយនិយាយថា **ម៉ា តេងទីន** ជាកូនក្មេង ។ ម្ដាយរបស់ **ម៉ា តេងទីន** បាននិយាយអង្វរថា យើងជាអ្នកក្រីក្រ ដូច្នេះហើយ ទើបខ្ញុំបណ្ដោយឲ្យកូនខ្ញុំ ធ្វើការដូចមនុស្សពេញវ័យ ដើម្បីទទួលបានប្រាក់ឈ្នួលដូចមនុស្សពេញវ័យ ដូច្នេះសូមមេត្តាផ្ដល់ឲ្យនាងនូវប្រាក់ឈ្នួលដូចមនុស្សពេញវ័យផង ។ **ឪរ ម៉្វាក់** បដិសេធ មិនព្រមឲ្យថ្លៃឈ្នួលនោះទេ ។ នេះជាការបោកប្រាស់ថ្លៃឈ្នួលពាក់កណ្ដាល របស់ **ម៉ា តេងទីន** ។ ដូច្នេះនៅពេល **ឪរ ម៉្វាក់** បានស្លាប់ទៅ នាងបានទៅចាប់កំណើត នៅក្នុងផ្ទៃនៃក្របីរបស់ **ម៉ា តេងទីន** ។ នាងកើតជាក្របីញី កើតកូនបានបី ក៏ស្លាប់ទៅ ។ នៅពេលយប់មុនពេលស្លាប់ **ម៉ាតេងទីន** សុបិនថា ក្របីញីនោះ មករកនាង ហើយឲ្យសាច់ដល់នាង ។ **ម៉ា តេងទីន មានគភ៌ ហើយសម្រាលកូនបាន ម៉ា ហ្វៃ** ដែលមានសាច់ពកដុះឡើងពីរដូចស្នែងនៅលើក្បាល ដើម្បីចង្អុលបង្ហាញថា អតីតជាតិរបស់នាងគឺ ជាក្របី ។ **ម៉ា ហ្វៃ** បានចាំកូនក្របីឈ្មោលទាំង ៣ របស់នាងក្នុងអតីតជាតិ ហើយទួញយំស្រក់ទឹកភ្នែក ចំពោះកូនទាំង ៣នោះ ។ បណ្ឌិត **អៀន ស្តេវ៉ិនសិន** បានមកប្រទេសមីយ៉ាម៉ា ដើម្បីពិនិត្យសង្កេតលើករណីនេះ[1]។

<u>យើងគួរវិភាគ រឿងនេះដែរ</u> ៖

តើយើងជឿថា ស្លាប់ ហើយកើតទៀតទេ ? ចំពោះខ្ញុំ សំណួរមិននៅត្រង់ ជឿ ឬ មិនជឿទេ ។ ពីព្រោះថា កាលណាយើងឃើញអ្វីមួយ ច្បាស់ដោយភ្នែកហើយ អត់មានអ្វីថា ជឿ ឬ មិនជឿនោះទេ ។ ឧបមាដូច ខ្ញុំក្ដាប់បាតដៃខ្ញុំជិត ខ្ញុំសួរទៅលោកអ្នកថា

[1] Dr. Mehm Tim Mom, « Two Paths for Future Existence », published in Myanmar Langage. Third Printing, p.195

« តើជឿថាខ្ញុំ បានក្តាប់លុយ ឬទេ ? » នោះលោកអ្នកខ្លះថាជឿថាមានលុយ លោកអ្នកខ្លះថាជឿថា អត់មានលុយ គឺបាតដៃទទេ។ យើងឆ្លើយបែបនេះ មកពីយើងពុំទាន់បានឃើញដោយភ្នែករបស់យើង ។ តែដល់ខ្ញុំលាបាតដៃហើយ នោះលោកអ្នកឃើញច្បាស់ដោយភ្នែកថា មាន ឬមិនមាន ស្រេចទៅហើយ ។

តែសំណួរដែល លោកអ្នកគួរសួរនៅពេលនេះ គឺថា **តើរឿងនោះ ពិត ឬ មិនពិត**។ នៅពេលនេះខ្ញុំឆ្លើយថា គួរប្រើបញ្ញារៀងៗខ្លួន ។ ចំពោះខ្ញុំ ដោយរឿងរបៀបនេះ ក៏ស្របនឹងធម៌ព្រះដែរ ហើយអ្នកសរសេររឿងនេះទៀត បានទៅឃើញផ្ទាល់ជាមួយលោក បណ្ឌិត **អៀន ស្តេវិនសិន** ខ្ញុំថាជារឿងពិត ។

លោកអ្នកអាចសួរថា តើហេតុអ្វី ក៏មនុស្សមិនចាំជាតិគ្រប់ៗគ្នាទៅ ? ខ្ញុំសូមឆ្លើយតាមការយល់ ការសង្កេតរបស់ខ្ញុំ ៖ មនុស្សយើងសព្វថ្ងៃនេះ មានការចាំមិនដូចគ្នាទេ អ្នកខ្លះគេមើលមេរៀនតែពីរបីចប់ គេចាំសូត្រគ្មានខុសមួយមាត់ ហើយអ្នកខ្លះរៀនមេរៀនដដែលមួយព្រឹកធំមិនទាន់ចាំផង ។ ដូច្នេះបើគ្រាន់តែក្នុងជាតិបច្ចុប្បន្ន នេះភ្លេចទៅហើយ ទំរាំតែស្លាប់ហើយកើតម្តងទៀតឲ្យចាំ នោះមិនងាយទេ ។ ត្រូវខំធ្វើធម្មទានសន្សំបុណ្យកុសល តទៅទៀត ។ ម្យ៉ាងទៀត យើងឃើញក្នុងរឿងនេះ នាង **ឌ័រ ម៉្វាក់** បដិសេធមិនព្រម ឲ្យប្រាក់ឈ្នួលទៅនាង **ម៉ា តេងទីន** ដូចជាមនុស្សពេញវ័យទេ ទុកជាម្តាយនាងនេះអង្វរយ៉ាងណាក៏ដោយ ។ ត្រង់នេះ យើងឃើញថានាង **ឌ័រ ម៉្វាក់** យកអំណាចមក កេងប្រវ័ញ្ចអ្នកក្រីក្រ ហើយថែមគ្មានធម៌មេត្តាទៀតផង។ ដល់នាងនេះមកកើតជាក្របីញី ត្រូវបាន នាង **ម៉ា តេងទីន** ជាម្ចាស់ក្របី (នេះមកពីជំពាក់ប្រាក់ឈ្នួល នាង**ម៉ា តេងទីន** កាលពីអតីតជាតិ) ។ ហើយក្របីញីនោះ មានកូនដល់ទៅ ៣ សុទ្ធតែជាក្របីឈ្មោល មុននឹងខ្លួនស្លាប់ ហើយ មកចាប់ជាតិជា កូនរបស់នាង **ម៉ា តេងទីន** ទៀត ដោយមានឈ្មោះថា នាង **ម៉ា ហ្វៃ**។ នាង **ម៉ា ហ្វៃ** ដោយចាំជាតិ

ឃើញក្របី ឈ្មោលទាំង៣ ដែលជារបស់ម្ដាយនាង ហើយ ដែលជា កូនរបស់នាងកាលពីជាតិមុន  ក៏ទួញយំស្រក់ទឹកភ្នែក ចំពោះកូនទាំង៣នោះ ។ នេះគ្រាន់តែឃើញកូនប៉ុណ្ណឹងស្រក់ទឹកភ្នែកទៅហើយ  ចុះដល់ថ្ងៃមុខបើគេយកក្របីទាំងនោះ ទៅប្រើដោយគ្មានធម៌មេត្តា ដូចកាលនាង ប្រើនាង **ម៉ា តេងទីន** ដោយគ្មានធម៌មេត្តាដែរនោះតើនាងមានទឹកឃើញទេថា "តើម្ដាយនាង **ម៉ា តេងទីន** កាលអតីតជាតិនោះ អាណិតកូនគាត់យ៉ាងណាដែរ?" (នេះហើយ កម្មពៀរ វាឆ្វងមិនចេះចប់ក្នុងវដ្ដសង្សារ) ។

<u>មតិទី៣</u>-  គឺពន្យល់តាមព្រះពុទ្ធសាសនា ដោយយកធម៌  **កម្ម ផល** ជាគោល ហើយ ធម៌នេះ អ្នកវិទ្យាសាស្ត្រ គេអាចយល់បាន  ពីព្រោះស្របនឹងច្បាប់ធម្មជាតិ។  ធម៌ព្រះពុទ្ធមួយទៀតគឺ  **ធម៌ទាំងឡាយ កើតមកអំពីហេតុ** (ដូច្នេះគ្មានអ្វី កើតដោយចៃដន្យទេ)។  តាមធម៌ព្រះពុទ្ធ មិនពិបាកយល់ទេ ៖

មនុស្សយើងម្នាក់ៗរស់នៅសព្វថ្ងៃតែងតែធ្វើអំពើណាមួយ ដោយ កាយ វាចា ឬចិត្ត ។ អំពើ តាមភាសាធម៌ ហៅថា កម្ម ។ កម្ម មានបួនប្រភេទ  គឺ **កម្មស** (កុសល)  **កម្មខ្មៅ** (អកុសល)  **កម្មសខ្លះខ្មៅខ្លះ  និង កម្មមិនស មិនខ្មៅ** (មិនកុសល មិនអកុសល)  ដែលគេហៅថា **កិរិយា  ប្រព្រឹត្តទៅដើម្បីអស់កម្ម** ។

តាមព្រះពុទ្ធសាសនា ចេតនាកម្ម[2]តែងតែឲ្យផល ជា កុសល ឬ ជា អកុសល ។ ចំពោះ កម្ម ដែលជា កិរិយា មានព្រះអរិយបុគ្គល ដូចជាព្រះសោតាបន្នបុគ្គលជាដើម លោកធ្វើដើម្បី រំលត់ទុក្ខ  ហើយកម្មព្រះអរហន្ត គឺ កម្មប្រព្រឹត្តទៅដើម្បីអស់កម្ម ពីព្រោះលោកដល់ត្រើយហើយ  ដូច្នេះលោកមិនត្រូវការកុសលអ្វីទៀតទេ ។ កុសលទុកដូចជាក្បូនសម្រាប់តែចម្លងលោក ពីត្រើយម្ខាង ទៅត្រើយម្ខាង។ ហេតុនេះហើយបានជាអំពើ

---

[2] ចេតនា គឺ ជា កម្ម ដែលធ្វើដោយមានបំណងជាក់ច្បាស់ ដោយគំនិតខ្លួនឯង ។

ដែលលោកធ្វើទាំងប៉ុន្មាន គឺសម្រាប់តែជួយសត្វលោកដែលត្រូវការសន្សំកុសល នៅឡើយ និង លះ អកុសល ។ ដោយយើងម្នាក់ៗ សុទ្ធតែនៅមានកុសល និង អកុសល ពីអតីតជាតិ និង បច្ចុប្បន្នជាតិ ដូច្នេះយើងត្រូវតែកើតទៀត ដើម្បី ទទួលផល នៃអំពើដែលយើងបានធ្វើ ។ នេះហើយ ការពន្យល់តាម ព្រះពុទ្ធសាសនា ដែលថា « ស្លាប់ហើយ កើតទៀត » ។ យើងអាចសួរថា ចំពោះព្រះអរហន្ត លោកធ្វើកិរិយា ក្នុងជាតិបច្ចុប្បន្ននេះពិតមែនហើយ តែដោយមានកម្មពីអតីតជាតិដែរ ហេតុអ្វី បានជាលោកមិនកើតទៀត ?

ចម្លើយគឺ ៖ ចំពោះព្រះ អរហន្ត លោកអស់កិលេសហើយ បន្ទាប់ពីចុតិទៅ លោកសម្រេច និព្វាន ដូច្នេះ តាមព្រះពុទ្ធសាសនាលោកមិនត្រឡប់កើតទៀតឡើយ ។ ក្រៅពីព្រះ អរហន្ត បន្ទាប់ពីចុតិទៅ សុទ្ធកើតទៀតទាំងអស់ ដូចជាព្រះអរិយខ្លះ កើត៧ដងទៀត ខ្លះកើតម្តងទៀត ខ្លះបរិនិព្វាននៅជាតិចុងក្រោយនោះតែម្តង ។

មតិទី៣ នេះ មិនដូចមតិទី១ទេ ពីព្រោះ មតិទី១ បើអ្នកនោះធ្លាប់កើតជា មនុស្សអ្នកក្រ នៅតែកើតជាមនុស្សអ្នកក្រដដែល ចំពោះមតិទី៣ កើតម្តងៗ ទៅតាមកម្មណាដែលឲ្យ ផល នៅពេលបដិសន្ធិ ។ ហើយ មតិទី៣ នេះ ក៏មិនដូចមតិទី២ ដែលថាស្លាប់ ហើយ មិនកើតទៀតទេ គឺសូន្យ ។ ពីព្រោះតាមព្រះពុទ្ធសាសនា ស្លាប់ហើយ មិនកើតទៀត លុះត្រាតែជាព្រះអរហន្ត ។ ទុកជាយើងយល់ថាមិនកើតទៀតក៏ដោយ ក៏នៅតែកើតជាថ្មីម្តងទៀតដែរ បើយើងជឿទៅលើច្បាប់ហេតុបច្ច័យ ឬ កម្មផល តែចិត្តនៅមានកិលេស គឺចិត្តមិនទាន់បរិសុទ្ធ នោះយើងនៅមាន លោភៈ ទោសៈ មោហៈ នៅឡើយ ដូច្នេះកម្មដែលយើងធ្វើ នៅជាកម្មស ឬ ជាកម្មខ្មៅនៅឡើយ ពុំទាន់ បាន ជាកម្មមិនស មិនខ្មៅនៅឡើយទេ ដូច្នេះត្រូវតែកើតទៀត ចង់ ឬមិនចង់ក៏ដោយ ។ ហើយឋានដែលនឹងទៅកើតទៀត ក៏មិនទៅតាមចំណង់យើងដែរ ។

*តើគួរខ្លាចពេលមុនដាច់ខ្យល់ស្លាប់ទេ ?*

*តាមធម្មតា អ្វីដែលយើងមិនដែលស្គាល់ យើងខ្លាច ដូចជាពេលមុនស្លាប់ជាដើម ។ ខ្ញុំធ្លាប់ឮគេនិយាយថា មានជនជាតិខ្មែរអ៊ីស្លាមម្នាក់ របររកទទួលទានគឺ កាប់គោ ។ ដល់ពេលគាត់ជិតដាច់ខ្យល់ គេឮគាត់ស្រែកដូចសម្លេងគោ ។ ខ្ញុំក៏ធ្លាប់មានសំណួរអំពីរឿងស្លាប់នេះដែរ ។ សំណួរខ្ញុំគឺ « ដោយយើងម្នាក់ៗ សុទ្ធតែបានធ្វើបុណ្យផង ហើយក៏បានធ្វើបាបខ្លះដែរ ចុះបើមុននឹងដាច់ខ្យល់ ចិត្តយើងមានអារម្មណ៍ទៅលើអំពើអកុសលណាមួយដែលបានធ្វើ តើយើងទៅកើតនៅឯណា ? » ។*

*ចម្លើយគឺ តាមធម៌អភិធម្ម គឺចិត្តចុងក្រោយនេះ ដែលផ្តល់ឲ្យចិត្តបដិសន្ធិ បន្តភពថ្មីតទៅទៀត បើចិត្តចុងក្រោយសោយអារម្មណ៍អកុសល នោះយើងទៅកើតនៅអបាយភូមិភ្លាម តែបើចិត្តចុងក្រោយ (ចុតិចិត្ត) សោយអារម្មណ៍កុសល នោះយើងកើតនៅ ឋានមនុស្ស ឬ ឋានទេវតា ។*

*ដូច្នេះចិត្តចុងក្រោយនេះសំខាន់ណាស់ ។ ពីព្រោះមនុស្សម្នាក់ៗថាឲ្យអស់បាបនោះ មិនងាយអស់ទេ យើងមើលអង្គុលីមាល បើកុំតែសម្រេចនិព្វានទាន់ នោះមិនដឹងជាអំពើអកុសល ចេញមកឲ្យផលនៅជាតិណាខ្លះទៀតទេ។ តែដល់អង្គុលីមាល បានសម្រេចព្រះនិព្វានហើយ នោះអកុសលកម្មទាំងនោះ ក៏គ្មានឱកាសនឹងឲ្យផលតទៅទៀត។ ដើម្បីមនុស្ស ជិតស្លាប់មានអារម្មណ៍ តែជាកុសល កូនចៅរបស់អ្នកជិតស្លាប់នោះ បានយកព្រះបដ មកដាក់តាមជញ្ជាំង និងតាំងនៅតាមពិតានផ្ទះ ហើយគេចាក់ស៊ីឌីធម៌ជូនគាត់ស្តាប់ ដែលជាជំនួយឲ្យគាត់ នឹកតែទៅអំពើល្អ <u>ដែលគាត់ធ្លាប់បានធ្វើ</u> ។ ចំពោះយើង បើខ្លាចអំពើអាក្រក់វាមកលង ដូចខ្មោច ត្រូវខំធ្វើអំពើល្អរាល់ៗថ្ងៃ កុំចាំជិតស្លាប់បាននឹកធ្វើ ។*

*<u>សង្កេត</u>*

ខ្ញុំយល់ថា ក្នុងមតិទាំង៣ មតិទី៣ មានប្រយោជន៍ជាង មតិទី២ និង មតិទី១ ទុកជាយើងមានជំនឿយ៉ាងណាក៏ដោយ។ ពីព្រោះអ្វី?

ពីព្រោះ មតិទី១ ធ្វើឲ្យមនុស្ស ខ្ជិល អស់សង្ឃឹមលើអនាគត មិនខំប្រឹងប្រែងធ្វើការងារ ពីព្រោះថា បើខំ ក៏នៅតែប៉ុណ្ណឹង មិនខំក៏នៅតែប៉ុណ្ណឹង ។ ដូច្នេះ ខំរៀនសូត្រ ឬបដិបត្តិធម៌ ធ្វើអំពើល្អ បានប្រយោជន៍អ្វី ។

ចំពោះ មតិទី២ ដោយថាស្លាប់ទៅសូន្យ ឥតមាននរក ឥតមានឋានសួគ៌ ដូច្នេះ សប្បាយ ឲ្យអស់ដៃទៅ ទាន់ខ្លួននៅរស់ ។ ចុះប្រសិនបើជាមាននរកវិញ អ្នកដែលមានមតិយ៉ាងនេះ មិនខាតធំទៅហើយ ។ ពីព្រោះថា ការពិតយ៉ាងណា វានៅតែយ៉ាងនោះ ដូច្នេះហើយបានជាខ្ញុំថា បើយើងអាចយល់ខុសដែរ នោះខ្ញុំយល់ថា ជ្រើសយក មតិទី៣ នាំឲ្យយើងមានអនាគតប្រសើរជាងយើងជ្រើសយក មតិទី១ ឬ មតិទី២ ។ ពីព្រោះមតិទី៣ នាំឲ្យយើងរស់នៅបានសេចក្ដីសុខសប្បាយទាំងក្នុងបច្ចុប្បន្ន ទាំងទៅអនាគត ដោយយើងប្រព្រឹត្តតែអំពើល្អ ចំពោះខ្លួនយើង និង ចំពោះអ្នកដទៃ ។

ព្រឹត្តិការណ៍ « ក្មេងរលឹកជាតិ » ជាកស្តុតាងមួយដែរ ចំពោះជំនឿថាស្លាប់ហើយកើតទៀត ហើយ ព្រឹត្តិការណ៍នោះ អាចពន្យល់តាមធម៌អភិធម្ម (ជាធម៌ព្រះពុទ្ធ)បាន ពីព្រោះក្នុង ធម៌អភិធម្ម <u>ចិត្ត កើតឡើង និង រលត់ទៅវិញ ជាងមួយកោដិដង បន្តបន្ទាប់គ្នាពល់**វិនាទី**</u> ដូច្នេះនៅពេលស្លាប់ បន្ទាប់ពី**ចុតិចិត្ត រលត់**ទៅភ្លាម នៅក្នុងបច្ចុប្បន្នភព **បដិសន្ធិចិត្ត ក៏កើត** ឡើងភ្លាមនៅក្នុងភពបន្ទាប់ (អនាគតភព) <u>ដោយគ្មានចន្លោះពេល</u> រវាង វិថីចិត្តក្នុងបច្ចុប្បន្នភព និង វិថីចិត្តនៃជីវិតបន្ទាប់ ។

ដូច្នេះ អ្វីៗដែលយើងបានរៀនសូត្រ ឬ បានពិសោធទាំងប៉ុន្មានក្នុងជីវិតនេះ ត្រូវបានកើតបន្តនៅវិថីចិត្តនៃជីវិតបន្ទាប់ ដែលជាហេតុ នាំឲ្យមានក្មេងជាច្រើននៅលើសកលលោក អាចចាំនូវអតីតជាតិរបស់ពួកគេបានយ៉ាងត្រឹមត្រូវ ហើយបានជាមានក្មេងមាន

*ទេពកោសល្យអាចចាំ និងសូត្រនូវអ្វីៗដែលពួកគេបានរៀនសូត្រក្នុងអតីតជាតិយ៉ាង អស្ចារ្យ ។ មកដល់ត្រង់នេះយើងឃើញថា ព្រលឹង និង វិថីចិត្ត ហាក់បីដូចជាមិនខុសគ្នា ។ តែបើយើងពិនិត្យ យើងឃើញខុសគ្នាត្រង់ ព្រលឹង គឺ រស់ជានិច្ច តែ វិថីចិត្ត គឺ កើតរលត់- រលត់កើត បន្តគ្នាមិនដែលដាច់សោះឡើយ ។*

*ជាចុងក្រោយ បើយើងជឿនូវការត្រាស់ដឹងនៃព្រះពុទ្ធ នៅក្នុងគម្ពីរព្រះសូត្រមានរឿង និទានជាច្រើន ស្តីពីព្រះពុទ្ធកាលដែលនៅជាព្រះពោធិសត្វនៅឡើយ ។ ព្រះអង្គបានចាប់ កំណើត ជា មនុស្ស ជាទេវតា ជាសត្វតិរច្ឆានក៏មាន។ ទាំងនេះសរឲ្យឃើញថាស្លាប់ ហើយកើតទៀត។ បើលោកអ្នកខ្លះថា រឿងទាំងនោះសុទ្ធតែប្រឌិត នោះស្រេចតែទៅ លើការយល់រៀងៗខ្លួនចុះ ។*